អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

# អត្ថបទប្រចាំខែ

លេខ ១៨/២៣ ចេញផ្សាយ ខែមិថុនា ឆ្នាំ២០២៣

# អត្ថប្រយោជន៍នៃការគ្រប់គ្រងប្រតិបត្តិការ

## និយមន័យនៃការគ្រប់គ្រងប្រតិបត្តិការ



ការគ្រប់គ្រងប្រតិបត្តិការ គឺសំដៅទៅលើការគ្រប់គ្រង ការអនុវត្តរបស់ស្ថាប័នដើម្បីទទួលបាននូវកម្រិតប្រសិទ្ធភាព និងប្រសិទ្ធផលអតិបរមាដែលទាក់ទងទៅនឹងការប្រើប្រាស់ធនធាន។ ការគ្រប់គ្រងប្រតិបត្តិការគឺពាក់ព័ន្ធនឹងសកម្មភាព ការសម្រេចចិត្ត និងទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រង ដើម្បីធានាបានថា ផលិតផល ឬសេវាផ្សេងៗ ដែលស្ថាប័នបានផ្តល់ជូនសាធារណជនមានគុណភាព និងមានអត្ថប្រយោជន៍ខ្ពស់។

## អត្ថប្រយោជន៍នៃការគ្រប់គ្រងប្រតិបត្តិការ

ការគ្រប់គ្រងប្រតិបត្តិការឱ្យបានល្អគឺផ្តល់នូវអត្ថ-ប្រយោជន៍ជាច្រើនដល់ស្ថាប័នទាំងមូល។ អត្ថប្រយោជន៍នៃការគ្រប់គ្រងប្រតិបត្តិការរួមមាន÷

**១. ការបង្កើនទំនុកចិត្តដល់សាធារណជន** គឺតាមរយៈការបង្ហាញពីភាពត្រឹមត្រូវ ពីភាពពេញនិយម ពីគុណភាព គុណតម្លៃនៃផលិតផល ឬសេវាកម្ម និងការគ្រប់គ្រងដំណើរការរបស់ស្ថាប័នឱ្យបានល្អ ដើម្បីបំពេញតម្រូវការចំណង់ចំណូលចិត្ត និងការរំពឹងទុករបស់សាធារណជន ក៏ដូចជា ការផ្តល់ផលិតផល ឬសេវាកម្ម ទាន់ពេលវេលា និងមានតម្លៃសមរម្យមានប្រសិទ្ធភាព។ នៅពេលដែលស្ថាប័នមួយអាច កសាងទំនុកចិត្តដល់សាធារណជនបាននោះ ផលិតផល ឬសេវាកម្មរបស់ស្ថាប័នក៏កាន់តែរីកចម្រើន ព្រមទាំងអាចកាត់បន្ថយលើការចំណាយក្នុងការផ្សព្វផ្សាយផងដែរគឺតាមរយៈ÷

- សាធារណជននឹងរីករាយក្នុងការផ្សព្វផ្សាយអំពីផលិតផល ឬសេវាកម្មរបស់ស្ថាប័ន
- សាធារណជននឹងហ៊ានចំណាយទៅលើផលិតផល ឬសេវាកម្មរបស់ស្ថាប័ន
- សាធារណជននឹងមានទំនុកចិត្តក្នុងការណែនាំ ផលិតផល ឬសេវាកម្មរបស់ស្ថាប័នទៅកាន់សាធារណជនដ៏ទៃ
- សាធារណជននឹងនៅតែបន្តប្រើប្រាស់ និងគាំទ្រផលិត-ផល ឬសេវាកម្មរបស់ស្ថាប័ន
- សាធារណជននឹងផ្តល់ការបញ្ចេញមតិយោបល់ដ៏ស្មោះត្រង់ ដល់ស្ថាប័នក្នុងការកែលម្អចំណុចខ្វះខាតឱ្យកាន់តែមានភាពល្អប្រសើរជាងមុន។

**២. ការកាត់បន្ថយជាអតិបរមានូវភាពខ្ជះខ្ជាយ** គឺផ្តោតទៅលើការប្រើប្រាស់ជាអតិបរមានៃធនធានទាំងអស់របស់ស្ថាប័ន ដោយកំណត់យុទ្ធសាស្ត្រសមស្របក្នុងការប្រើ-ប្រាស់ធនធាន និងបន្តប្រតិបត្តិជាបន្តបន្ទាប់។ អ្នកគ្រប់គ្រងប្រតិបត្តិការគឺត្រូវធ្វើការគ្រប់គ្រងរាល់សកម្មភាពទាំងអស់របស់ស្ថាប័ន និងធានាបានថាធនធានរបស់ស្ថា-ប័នទាំងអស់ដែលបានប្រើប្រាស់មានប្រយោជន៍ និងមិនប្រើប្រាស់ខ្ជះខ្ជាយ។

**៣. ការបង្កើនផលចំណេញសម្រាប់ស្ថាប័ន** ស្ថាប័នមួយនឹងទទួលបាននូវប្រាក់ចំណេញ និងកេរ្តិ៍ឈ្មោះដ៏ល្អឥតខ្ចោះដោយសារតែគុណភាពផលិតផល ឬសេវាកម្ម របស់ស្ថាប័ន ក៏ដូចជាការពេញចិត្តពីសំណាក់សាធារណជនផងដែរ។ ទាំងអស់នេះជាកត្តាជំរុញឱ្យប្រាក់ចំណូលរបស់ស្ថាប័នកាន់តែកើនឡើង ដោយសារតែការគាំទ្ររបស់សាធារណជន។

**អត្ថបទ÷ លោក រ៉ូ ម៉ុនណារ៉ុង**

**ឯកសារយោង÷**

ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.**



ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ស្កេនទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត